ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# បទបញ្ញត្តិទូទៅ
# សម្រាប់បេក្ខជន បេក្ខនារី ប្រឡងប្រជែងចូលបម្រើការងារជាមន្ត្រីក្របខណ្ឌថ្មី ០៨នាក់ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# នៅថ្ងៃព្រហស្បតិ៍ ៥កើត ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
# ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងវិន័យ បេក្ខជន បេក្ខនារី ចូលរួមប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីឆ្នាំ២០២៣ ត្រូវគោរពបទបញ្ញត្តិទូទៅ ដូចខាងក្រោម៖

ក. បេក្ខជន បេក្ខនារី ត្រូវ ៖

១. មកដល់មណ្ឌលប្រឡងយ៉ាងតិច ៣០នាទី មុនពេលដំណើរការនៃការប្រឡង

២. យកមកជាមួយនូវអត្តសញ្ញាណប័ណ្ណ និងបង្កាន់ដៃប្រឡង

៣. អង្គុយតាមលេខតុដែលបានកំណត់ដោយគណៈកម្មការប្រឡង

៤. ឱ្យមន្ត្រីអនុរក្សឆែក និងដកហូតឯកសារ ដែលក្រសួងមិនអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡង

៥. ប្រគល់សន្លឹកកិច្ចការជូនមន្ត្រីអនុរក្ស នៅពេលបញ្ចប់ម៉ោងប្រឡង ទោះបីកិច្ចការនោះធ្វើពុំទាន់ចប់ក៏ដោយ។

ខ. បេក្ខជន បេក្ខនារី មិនត្រូវ ៖

១. ចូលក្នុងបន្ទប់ប្រឡងមុនពេលមន្ត្រីអនុរក្សហៅឈ្មោះ

២. ស្លៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ និងសម្លៀកបំពាក់មិនសមរម្យចូលក្នុងបន្ទប់ប្រឡង

៣. យកទូរស័ព្ទដៃ ឬគ្រឿងអេឡិកត្រូនិចផ្សេងៗ ចូលក្នុងបន្ទប់ប្រឡង

៤. យកអាវុធជាតិផ្ទុះចូលក្នុងបន្ទប់ប្រឡង

៥. ប្រើពាក្យសំដី ឬអាកប្បកិរិយាមិនសមរម្យទៅលើគណៈមេប្រយោគ និងមន្ត្រីអនុរក្សនៅក្នុងបន្ទប់ប្រឡង

៦. សរសេរចម្លើយវិញ្ញាសានៅលើក្រដាសកិច្ចការ ដែលគ្មានហត្ថលេខារបស់មន្ត្រីអនុរក្ស

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

៧. ចម្លងសំណួរវិញ្ញាសាចូលក្នុងក្រដាសកិច្ចការផ្សេង ឬបោះសំណួរវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង

៨. ដើរបណ្ដើរ ងាកឆ្វេង-ស្ដាំ ឬដើរចេញពីកន្លែងប្រឡង ដោយគ្មានការអនុញ្ញាតពីមន្ត្រីអនុរក្ស

៩. ឡូឡា ឬទាញយកក្រដាសកិច្ចការរបស់អ្នកដទៃមកចម្លង

១០. ប្ដូរគ្នានូវក្រដាសកិច្ចការ ក្រដាសព្រាង ផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា និងដាក់ក្រដាសកិច្ចការឆ្ងាយពីមុខរបស់ខ្លួន ដើម្បីឱ្យអ្នកដទៃមើល ឬទាញយកបានឡើយ

១១. សរសេរប៊ិចផ្សេងក្រៅពីប៊ិចដែលចែកជូន

១២. ធ្វើសញ្ញាសម្គាល់លើក្រដាសកិច្ចការរបស់ខ្លួន ដូចជា៖ ការសរសេរអក្សរប្លែកពីតួអក្សរទាំងអស់ក្នុងកិច្ចការ សញ្ញាផ្សេងៗ ឬគូរបន្ទាត់ខុសប្រក្រតី

១៣. លាក់ ឬហែកក្រដាសកិច្ចការរបស់ខ្លួន និងអ្នកដទៃ

១៤. ធ្វើឱ្យខូចខាត ឬបាក់បែកសម្ភារៈនៅក្នុងបន្ទប់ប្រឡង

១៥. ឱ្យអ្នកដទៃប្រឡងជំនួស ឬសរសេរបំពេញបន្ថែមលើក្រដាសកិច្ចការរបស់ខ្លួន ជាដាច់ខាត

១៦. បង្កសកម្មភាព ដែលនាំឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ និងរបៀបរៀបរយ នៃការប្រឡង។

ក្នុងករណីបេក្ខជន បេក្ខនារីណាម្នាក់ បំពានចំណុចណាមួយ ដូចដែលមានចែងក្នុងបទបញ្ញត្តិខាងលើ គណៈកម្មការរៀបចំការប្រឡងមានសិទ្ធិឱ្យបេក្ខជន បេក្ខនារី បោះបង់ការប្រឡងដោយស្វ័យប្រវត្តិ។

ថ្ងៃ ពុធ ៤កើត ខែ ប.សាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២៣

**ជ. ប្រធានគណៈកម្មការរៀបចំការប្រឡង**

**អនុប្រធាន**

**អ៊ុច បូររិទ្ធ**